# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧០**

**ស្តីពីការបង្កើត**

**និងគ្រប់គ្រងតំបន់ជីវមណ្ឌលបឹងទន្លេសាប**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានទ្រង់យល់ក្រឹត្យច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនាឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល

.-បានទ្រង់យល់លក្ខន្តិកៈនៃប្រព័ន្ធតំបន់ជីវមណ្ឌលពិភពលោក ដែលបានអនុម័តនៅក្នុងមហាសន្និបាតទូទៅរបស់ អង្គការ យូណេស្កូ នៅថ្ងៃទី ២០ ដល់ ២៥ ខែមិនា ឆ្នាំ ១៩៩៥

-បានទ្រង់យលសេចក្តីសំរេចទទួលស្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិ សំរាប់កម្មវិធីមនុស្ស និងជីវមណ្ឌលរបស់អង្គការយូណេស្កូ ក្នុងការបញ្ចូលបឹងទន្លេសាប ទៅក្នុងប្រព័ន្ធថបនីយជីវមណ្ឌលពិភពលោក នៅក្នុងសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសំរបសំរួល អន្តរជាតិ នៅថ្ងៃទី ២៧.-២៩ខែតុលា ឆ្នាំ ១៩៩៧

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃ ទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០១

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតថបនីយជីវមណ្ឌលបឹងទន្លេសាប ដោយផ្អែកលើសារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌បឹងទន្លេសាប ស្របតាមលក្ខន្តិកៈស្តីពីប្រព័ន្ធ ថបនីយជីវមណ្ឌលពិភពលោក ។ការបង្កើតថបនីយជីវមណ្ឌលបឹងទន្លេសាបនេះ មានគោលបំណងសំខាន់ ៣ គឺ :

១-អភិរក្សជីវចំរុះ ទេសភាព សណ្ឋានដី និងប្រព័ន្ធអេកូឡូស៊ី រួមទាំងធនធានសេនេទិច ប្រភេទរុក្ខជាតិ មច្ឆាជាតិ និងសត្វ ព្រមទាំងស្តារឡើងវិញនូវបរិស្ថាន និងទីជម្រកនៃជីវចំរុះ ។

២-ទ្រទ្រង់ឱ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពលើប្រព័ន្ធអេកូឡូស៊ីបរិស្ថានសេដ្ឋកិច្ច សង្គម និង វប្បធម៌

៣- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការអនុវត្តគម្រោងបង្ហាញ ការអប់រំបណ្តុះបណ្តាលការសិក្សា-ស្រាវជ្រាវ និងការអង្កេតតាមដានការប្រែប្រួលបរិស្ថាន ដែលទាក់ទង នឹងការអភិវឌ្ឍន៍ដោយនិរន្តរភាព ការអភិរក្សនៅក្នុងកំរិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ ។

## ជំពូកទី ២

## ទីតាំងភូមិសាស្ត្រនៃថបនីយជីវមណ្ឌលបឹងទន្លេសាប

**មាត្រា២.-**ដើម្បីអនុវត្តនូវគោលបំណងសំខាន់ទាំងបី ដូចបានកំណត់ក្នុងមាត្រា ១ ថបនីយជីវមណ្ឌល បឹងទន្លេសាប ត្រូវបែងចែកជាបីតំបន់គឺ តំបន់ស្នូល តំបន់ទ្រនាប់ និងអន្តរតំបន់ ។

ថបនីយជីវមណ្ឌលបឹងទន្លេសាបមានព្រំប្រទល់ ខាងលិចទល់នឹងផ្លូវជាតិលេខ៥ ខាងកើតទល់នឹងផ្លូវជាតិលេខ ៦ ខាងជើងកំណត់ត្រឹមចំណុចប្រសព្វ នៃផ្លូវជាតិលេខ៥ និងលេខ៦ ( 13° 36’52’’N,103° 06’32’’E ) និងខាងត្បូងត្រឹមឃុំសែប ( 12° 05’ 06 N 104° 43 39 E) ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ផែនទីព្រំប្រទល់ និងនិយាមការនៃថបនីយមណ្ឌលបឹងទន្លេសាប មានក្នុងឧបសម្ពន្ធ័ទី១ និងឧបសម្ពន្ធ័ទី២ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

តំបន់ស្នូលមានបីគឺ :

១-តំបន់ស្នូលព្រែកទាល់ មានទីតាំងស្ថិតនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ហើយមានផ្ទៃក្រឡា ២១.៣៤២ ហិកតា ។

២-តំបន់ស្នូលបឹងទន្លេឆ្មារ មានទីតាំងនៅស្ថិតក្នុង ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ហើយមានផ្ទៃក្រឡា១៤.៥៦០ ហិកតា ។

៣-តំបន់ស្នូលស្ទឹងសែន មានទីតាំងស្ថិតនៅក្នុង ឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ហើយមានផ្ទៃក្រឡា ៦.៣៥៥ ហិកតា ។

តំបន់ស្នូលមានសារៈប្រយោជន៍ និងតំលៃស្មើនឹងឧទ្យានជាតិ ឬដែនជំរកសត្វព្រៃ ដែលកំណត់សម្រាប់ការពារ និងអភិរក្សយូរអង្វែងនូវធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ដើម្បីរក្សាអោយបានគង់វង្សនូវព្រៃលិចទឹក មច្ឆាជាតិ សត្វព្រៃគ្រប់ប្រភេទ ប្រពន្ធ័ជលសាស្ត្រ និងសោភណភាពនៃធម្មជាតិ ។ តំបន់ស្នូលអនុញ្ញាតឱ្យមានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រការអង្កេតតាមដាន និងអេកូទេសចរណ៍។ តំបន់នេះមិនអនុញ្ញាតឱ្យមានសកម្មភាពណាមួយ ដែលធ្វើឱ្យរេចរិល ឬបំផ្លាញជីវចម្រុះឡើយ ។

ឡូត៍នេសាទ ដែលមានតំបន់ស្នូលស្ថិតនៅខាងក្នុងនឹងបន្តធ្វើអាជីវកម្មស្របតាមច្បាប់ជលផលហើយម្ចាស់ឡូត៍នេសាទត្រូវយកចិត្តទុកដាក់ចូលរួមចំណែកអនុវត្តនូវទិសដៅអភិរក្សយូរអង្វែងដូចបានកំណត់ខាងលើ ។ ឡូត៍នេសាទទាំងនេះត្រូវទទួលការត្រួតពិនិត្យ និងវាយតម្លៃ ក្នុងរយៈពេល ៤ឆ្នាំម្តង ហើយត្រូវធ្វើកំណែទម្រង់សមស្របដើម្បីឱ្យស៊ីសង្វាក់ទៅនឹងទិសដៅការពារ និងអភិរក្សយូរអង្វែងនៃតំបន់ស្នូល ។

ការនេសាទរបស់ប្រជាពលរដ្ឋជាលក្ខណៈគ្រួសារ និងលក្ខណៈសិប្បកម្មដែលស្ថិតនៅក្នុងតំបន់ស្នូលខាងក្នុងត្រូវបន្តអាជីវកម្ម ស្របតាមច្បាប់ជលផលដោយមានការរៀបចំជាសហគមន៍នេសាទ ដើម្បីចូលរួមការពារស្របតាមស្មារតីព្រះរាជក្រឹត្យ ។

**មាត្រា៤.-**

តំបន់ទ្រនាប់មានផ្ទៃក្រឡា៥៤១.៤៨២ហិកតា ដែលមានព្រំប្រទល់ត្រួតស៊ីគ្នានឹងព្រំប្រទល់ខាងក្រៅនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង នៃបឹងទន្លេសាប ។ តំបន់ទ្រនាប់ជាតំបន់ព័ទ្ធជុំវិញតំបន់ស្នូល ដែល គ្របដណ្តប់ដោយព្រៃលិចទឹកគ្រប់ប្រភេទ។

សកម្មភាពរបស់មនុស្សត្រូវបានគ្រប់គ្រងឱ្យបានសមស្រប ដោយស៊ីសង្វាក់នឹងផែនការការពារ និងអភិរក្សនៃតំបន់ស្នូល ។ សកម្មភាពនេសាទនិងអភិវឌ្ឍន៍ផ្សេងៗនឹងបន្តដំណើរ ការគ្រប់គ្រងដោយច្បាប់ដែលមានស្រាប់ដោយឈរលើស្មារតីសហការ និងសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ ។ តំបន់នេះ ក៏ជាកន្លែងសំរាប់ការពិសោធន៍ ស្រាវជ្រាវនូវវិធីសាស្ត្រគ្រប់គ្រងព្រៃលិចទឹក នេសាទកសិកម្ម ការតាំងលំនៅដ្ឋាន ការប្រើប្រាស់ដីធ្លីធនធានទឹក នាវាចរណ៍ ទេសចរណ៍ដែលអាច-ធានានិរន្តរភាព បង្កើនផលិតកម្មដោយរក្សាឱ្យបាននូវគុណភាពបរិស្ថាន និងមច្ឆជាតិ ។

**មាត្រា៥.-**

អន្តរតំរេធំជាតំបន់នៅជុំវិញតំបន់ទ្រនាប់ មានផ្ទៃដី ៨៩៥.៦០០ហិកតា ស្ថិតនៅចន្លោះព្រំប្រទល់តំបន់ទ្រនាប់និងផ្លូវជាតិលេខ៦ និងលេខ ៥ ។

អន្តរតំបន់ជាតំបន់សេដ្ឋកិច្ចចម្រុះ ត្រូវរៀបចំឱ្យបានសមស្របសំដៅធានានិរន្តរភាពកសិកម្ម ការតាំងលំនៅដ្ឋាន និងការប្រើប្រាស់ដីផ្សេងៗដោយមិនធ្វើឱ្យមានឥទ្ធិពលអាក្រក់ទៅលើព្រៃលិចទឹក គុណភាពទឹក និងដី នៅក្នុងតំបន់ជុំវិញបឹងទន្លេសាប ។

## ជំពូកទី III

## រដ្ឋបាល និងការគ្រប់គ្រង

**មាត្រា៦.-**

ដើម្បីជួយសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ក្នុងកិច្ចការពារ និងគ្រប់គ្រងជីវមណ្ឌលបឹងទន្លេសាបប្រកបដោយនិរន្តរភាពចាំបាច់ត្រូវបង្កើតលេខាធិការដ្ឋានជីវមណ្ឌលបឹងទន្លេសាបដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។ ការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានជីវមណ្ឌលបឹងទន្លេសាបត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៧.-**

ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការគ្រប់គ្រង ការធ្វើផែនការការពារ និងអភិរក្សតំបន់ស្នូលនៃជីវមណ្ឌលបឹងទន្លេសាប តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាននិងអាជ្ញាធរដែនដី ផ្អែកលើ មាត្រា៣នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៤
## ការកែប្រែព្រំប្រទល់

**មាត្រា៨.-**

ការគ្រប់គ្រងតំបន់ទ្រនាប់ និងអន្តរតំបន់ ត្រូវអនុវត្តតាមផែនការរបស់ក្រសួងជំនាញពាក់ព័ន្ធ តាមរយៈការសំរបសំរួលរបស់គណៈកម្មាធិការជាតិទន្លេ មេគង្គកម្ពុជា ស្របតាមមាត្រា៤និងមាត្រា ៥ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៩.-**

ព្រំប្រទល់ និងសកម្មភាពនៃតំបន់នីមួយៗនៃ ជបនីយជីវមណ្ឌលបឹងទន្លេសាបនេះ អាចនឹងកែប្រែបាន ដោយផ្អែកលើពត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងដែលទាក់ទងទៅនឹងការ អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការអភិរក្សជីវចម្រុះ និងរក្សាការពារនិរន្តរភាពបរិស្ថាន ដូចចែងក្នុងមាត្រា ៣ មាត្រា៤ និងមាត្រា៥នៃព្រះរាជក្រឹត្យនេះ ។

ការកែប្រែព្រំប្រទល់និងសកម្មភាពនៃតំបន់នីមួយៗនៃ ជបនីយជីវមណ្ឌលបឹងទន្លេសាប ត្រូវកំណត់ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថានដោយមានការយល់ព្រមពីក្រសួងស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-** បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

ហត្ថលេខា

**ម៉ុក ម៉ារ៉េត**